ពុទ្ធមណ្ឌលវិបស្សនាធុរៈ
នៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ធម្មបទគាថា មគ្គវគ្គ ទី ២០

## បិដកលេខ ៥២ ទំព័រ ៧៨-៨១

(៣០)មគ្គានដ្ឋង្គិកោ សេដ្ឋោ          សច្ចានំ ចតុរោ បទា

វិរាគោ សេដ្ឋោ ធម្មានំ          ទ្វិបទានញ្ច ចក្ខុមា ។

ផ្លូវមានអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយ បទ ៤ គឺអរិយសច្ចប្រសើរជាងសច្ចៈទាំងឡាយ វិរាគធម៌ប្រសើរជាងធម៌ទាំងឡាយ ម្យ៉ាងទៀត ព្រះតថាគតមានចក្ខុ ប្រសើរជាងសត្វទ្វេបាទ ទាំងឡាយ។

ឯសេវ មគ្គោ នត្ថញ្ញោ          ទស្សនស្ស វិសុទ្ធិយា

ឯតញ្ហិ តុម្ហេ បដិបជ្ជថ          មារស្សេតំ បមោហនំ ។

ផ្លូវនេះឯង ប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃទស្សនៈ ផ្លូវដទៃមិនមានទេ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរដើរទៅកាន់ផ្លូវនោះ ផ្លូវនេះជាផ្លូវញុំាងមារឲ្យវង្វេង។

ឯតញ្ហិ តុម្ហេ បដិបន្នា          ទុក្ខស្សន្តំ ករិស្សថ

អក្ខាតោ វេ មយា មគ្គោ          អញ្ញាយ សល្លសន្ថនំ ។

អ្នកទាំងឡាយដើរទៅកាន់ផ្លូវនេះហើយ អាចនឹងធ្វើអោយផុតទុក្ខបាន ផ្លូវនេះហើយដែលតថាគតថាជាផ្លូវកំចាត់បង់កូនសរ ប្រាប់អ្នកទាំងឡាយ។

តុម្ហេហិ កិច្ចមាតប្បំ          អក្ខាតារោ តថាគតា

បដិបន្នា បមោក្ខន្តិ          ឈាយិនោ មារពន្ធនា ។

សេចក្តីព្យាយាមញុំាងកិលេសអោយក្តៅសព្វ អ្នកទាំងឡាយគប្បីធ្វើ ព្រះតថាគតទាំងឡាយគ្រាន់តែជាអ្នកប្រាប់ ជនទាំងឡាយមានការពិនិត្យ បើបានដើរទៅហើយ នឹងរួចចាកចំណងរបស់មារបាន។

សព្វេ សង្ខារា អនិច្ចាតិ          យទា បញ្ញាយ បស្សតិ

អថ និព្វិន្ទតិ ទុក្ខេ          ឯស មគ្គោ វិសុទ្ធិយា ។

កាលណាបុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងមិនទៀង ដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ។

សព្វេ សង្ខារា ទុក្ខាតិ     យទា បញ្ញាយ បស្សតិ
អថ និព្ពិន្ទតិ ទុក្ខេ     ឯស មគ្គោ វិសុទ្ធិយា ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងនាំមកនូវសេចក្តីទុក្ខ ដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ។

សព្វេ ធម្មា អនត្តាតិ     យទា បញ្ញាយ បស្សតិ
អថ និព្ពិន្ទតិ ទុក្ខេ     ឯស មគ្គោ វិសុទ្ធិយា ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងមិនមែនជារបស់ខ្លួន ដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ។

ឧដ្ឋានកាលម្ហិ អនុដ្ឋហានោ     យុវា ពលី អាលសិយំ ឧបេតោ
សំសន្នសង្កប្បមនោ កុសីតោ     បញ្ញាយ មគ្គំ អលសោ ន វិន្ទតិ ។

បុគ្គលនៅកំឡោះមានកំលាំង ទាស់តែប្រកបដោយសេចក្តីខ្ជិលច្រអូស មិនប្រឹងប្រែង ក្នុងកាលដែលគួរប្រឹងប្រែង មានសេចក្តីត្រិះរិះក្នុងចិត្ត លិចចុះ ក្នុងអកុសលវិតក្កៈ ជាមនុស្សខ្ជិល បុគ្គលខ្ជិលនោះរមែងមិនបានផ្លូវបញ្ញាឡើយ។

វាចានុរក្ខី មនសា សុសំវុតោ     កាយេន ច អកុសលំ ន កយិរា
ឯតេ តយោ កម្មបថេ វិសោធយេ     អារាធយេ មគ្គមិសិប្បវេទិតំ ។

បុគ្គលគប្បីជាអ្នករក្សាវាចា សង្រួមអោយល្អ ដោយមិត្ត ទាំងមិនគប្បីធ្វើអកុសលដោយកាយ បុគ្គលគប្បីជំរះកម្មបទទាំង៣ នេះ នឹងគប្បីត្រេតអរចំពោះមគ្គ ដែលលោកអ្នកស្វែងរកគុណ ដ៏ល្អ សម្តែងទុកហើយ ។

. យោគា វេ ជាយតី ភូរិ     អយោគា ភូរិសង្ខយោ
ឯតំ ទ្វេធាបថំ ញត្វា     ភវាយ វិភវាយ ច
តថាត្តានំ និវេសេយ្យ     យថា ភូរិ បវឌ្ឍតិ ។

ប្រាជ្ញា រមែងកើតអំពីការប្រកប សេចក្តីវិនាសប្រាជ្ញា រមែងកើតអំពីការមិនប្រកប អ្នកមានប្រាជ្ញាដឹងការប្រកប និងការមិនប្រកប ទាំពីរនេះថា ជាគន្លងនៃសេចក្តីចំរើន និងសេចក្តីវិនាសហើយ ប្រាជ្ញាចំរើនឡើយដោយប្រការណា គួរដំកល់ខ្លួនទុក ដោយប្រការ

នោះ។

វនំ ឆិន្ទថ មា រុក្ខំ　　　　វនតោ ជាយតិ ភយំ
ឆេត្វា វនញ្ច វនថញ្ច　　　　និព្វនា ហោថ ភិក្ខវោ ។

អ្នកទាំងឡាយចូរកាត់កិលេសដូចជាព្រៃចេញ ចូរកំចាត់ដើមឈើ ព្រោះភ័យកើតអំពីកិលេស ដូចជាព្រៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរកាត់កិលេសដូចជាព្រៃឈើផង កិលេសដូចជាដើមឈើដុះក្នុងព្រៃផង។

យាវ ញ្ហិ វនថោ ន ឆិជ្ជតិ　　　　អណុមត្តោបិ នរស្ស នារិសុ
បដិពទ្ធមនោវ តាវ សោ　　　　វច្ឆោ ខីរបកោវ មាតរិ ។

ចូរជាអ្នកកុំមានកិលេស ដូចជាព្រៃឡើយ ព្រោះថាកិលេសដូចជាព្រៃឈើដុះក្នុងព្រៃរបស់នរជន សូម្បីមានប្រមាណតិចក៏ដោយ បើកាត់មិនដាច់កក្នុងពួកនារីដរាបណា នរជននោះឯង តែងមានចិត្តចំពោះក្នុងពួកនារី ដូមកូនគោនៅក្នុងបៅដោះ ដែលមានចិត្តជាប់នៅនឹងមេ ដរាបនោះ។

ឧច្ឆិន្ទ សិនេហមត្តនោ　　　　កុមុទំ សារទិកំវ ចាណិនា
សន្តិមគ្គមេវ ព្រូហយ　　　　និព្វានំ សុគតេន ទេសិតំ ។

អ្នកចូរដកសេចក្តីស្រឡាញ់របស់ខ្លួនចេញ ដូចបុគ្គល ដកផ្កាកុមុខ ដែលកើតក្នុងសរទកាលដោយដៃ អ្នកចូរបណ្តុះនូវផ្លូវសន្តិភាពតែម្យ៉ាង ព្រះនិព្វាន ព្រះសុគតសំដែងទុកហើយ។

ឥធ វស្សំ វសិស្សាមិ　　　　ឥធ ហេមន្តគិម្ហិសុ
ឥតិ ពាលោ វិចិន្តេតិ　　　　អន្តរាយំ ន ពុជ្ឈតិ ។

អញនឹងនៅក្នុងទីនេះអស់វស្សានរដូវ អញនឹងនៅក្នុងទីនេះក្នុងហេមន្តរដូវនិងគិម្ហរដូវ ជនពាល រមែងគិតខុសដូច្នេះ តែងមិនដឹងច្បាស់សេចក្តីអន្តរាយឡើយ។

តំ បុត្តបសុសម្មត្តំ　　　　ព្យាសត្តមនសំ នរំ
សុត្តំ គាមំ មហោឃោវ　　　　មច្ចុ អាទាយ គច្ឆតិ ។

មច្ចុគឺសេចក្តីស្លាប់ តែងនាំយកនរជន អ្នកស្រវឹងជ្រប់ ក្នុងកូននិងសត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ ក្នុងអារម្មណ៍ផ្សេងៗនោះ ដូចជំនន់ទឹកធំ នាំយកអ្នកស្រុកកំពុងដេកលក់។

ន សន្តិ បុត្តា តាណាយ　　　　ន បិតា នាបិ ពន្ធវា

អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា ។

កាលបុគ្គលត្រូវមច្ចុសង្កត់ហើយ កូនទាំងឡាយ មិនមានដើម្បីជាទីពឹង បិតាក៏មិនមាន ទាំងផៅពង្សក៏មិនមាន ដើម្បីជាទីពឹងឡើយ ។

ឯតមត្ថវសំ ញត្វា បណ្ឌិតោ សីលសំវុតោ

និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ ។

សេចក្តីទីពឹងក្នុងញាតិទាំងឡាយក៏មិនមាន បណ្ឌិតដឹងអំណាចប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់ជម្រះផ្លូវជាទីកាន់ព្រះនិព្វានឲ្យបាន។

**សព្វទានំ ធម្មទានំ ជិនាតិ !**


*អាសយដ្ឋាន:* *ពុទ្ធមណ្ឌលវិបស្សនាធុរៈនៃព្រះរាជាណាចក្រកម្ពុជា*

*ភ្នំអដ្ឋវង្ស ឃុំផ្សាររដែក ស្រុកពញាឮ ខេត្តកណ្តាល កម្ពុជា*

*វេបសាយ:* BVDCC.org

*យូធូប/ផេក:* *ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា*

ឬ Vipassana Dhurak Buddhist Centre

*អ៊ីម៉ែល:* chhenchhoun@gmail.com


**សូមអរព្រះគុណ និងអរគុណ !**